ស.ផ.ក.ក.
COSECAM

សម្ព័ន្ធអង្គការក្រៅរដ្ឋាភិបាលដើម្បីដោះស្រាយបញ្ហា
កេងប្រវ័ញ្ច (ផ្លូវភេទ) លើកុមារក្នុងប្រទេសកម្ពុជា

## សៀវភៅណែនាំទម្រង់ខ្លី

# ការគ្រប់គ្រងករណី
# ដោយកិច្ចសម្របសម្រួល

# ក គ ស

ប្រព័ន្ធសម្របសម្រួលថ្នាក់ជាតិសម្រាប់ការផ្ញើមជ្ឈការសេវា
ទៅដល់ជនរងគ្រោះនៃការកេងប្រវ័ញ្ច និងអំពើហិង្សា

តុលា ២០០៨

ការបង្កើតឱ្យមានបរិស្ថានមួយ ប្រកបដោយនីត្យានុកូល

និងនិរន្តរភាពសម្រាប់ជនរងគ្រោះបានគេជួញដូរ ទាំងនៅក្នុងនិងក្រៅប្រទេសកម្ពុជា

(គម្រោងសិតកាំ)

# ការគ្រប់គ្រងករណីដោយកិច្ចសម្របសម្រួល

# (គកស)

ប្រព័ន្ធសម្របសម្រួលថ្នាក់ជាតិសម្រាប់ការធ្វើមផ្សការសេវាទៅដល់

ជនរងគ្រោះនៃការកេងប្រវ័ញ្ច និងអំពើហិង្សា

# សៀវភៅណែនាំទម្រង់ខ្លី

# គ ក ស

រៀបចំដោយ : ក្រុមការងារគម្រោងសិតកាំ

តុលា ២០០៨

# **មាតិកា**

**ទំព័រ**


ការបោះពុម្ពផ្សាយ .................................................................................................. ០១

អ្នករួមវិភាគទាន .................................................................................................. ០១

តើមូលហេតុអ្វីដែលបង្កើតឱ្យមានសៀវភៅណែនាំនេះ ? ............................................................ ០២

ការវិភាគបញ្ហា .................................................................................................. ០៣

វិធីសាស្ត្ររួមនៃប្រព័ន្ធ *គកស* .................................................................................. ០៦

ប្រព័ន្ធទំនាក់ទំនងការងារ .......................................................................................... ០៨

ការិយាល័យ *គកស* ខេត្ត .......................................................................................... ០៩

គណៈកម្មការធនធានមូលដ្ឋាននៃ *គកស* ............................................................................ ១០

ក្រុមអ្នកត្រួតពិនិត្យនៃ *គកស* .................................................................................... ១១

ក្រុមអ្នកប្រឹក្សាយោបល់នៃ *គកស* ................................................................................ ១១

ដំណាក់កាលទាំង ១០ នៃដំណើការ *គកស* ........................................................................ ១២

គម្រោងសាកល្បង .................................................................................................. ១៩

យន្តការត្រួតពិនិត្យ .................................................................................................. ២០

តួនាទី និងការទទួលខុសត្រូវ ...................................................................................... ២៣

ការត្រួតពិនិត្យ និងវាយតម្លៃ ...................................................................................... ២៦

## ការបោះពុម្ពផ្សាយ

សៀវភៅណែនាំដែលមានទម្រង់ខ្លីស្ដីអំពី *គកស* ក៏ដូចជាសៀវភៅយោង ដែលជាប្រភពដើមនៃសេចក្ដីណែនាំទម្រង់ខ្លី *គកស* នេះត្រូវបានផ្ដល់ការឧបត្ថម្ភគាំទ្រពីសហគមន៍អឺរ៉ុប ។

## អ្នករួមចំណែក

សៀវភៅណែនាំនេះគឺជាលទ្ធផលដែលបានមកពីការខិតខំប្រឹងប្រែងរបស់បុគ្គលិក និងភ្នាក់ងារដែលមានឈ្មោះដូចខាងក្រោម :

- លោកស្រី ផូឡា ស្រេតតុន បុគ្គលិកស្ម័គ្រចិត្តផ្នែកច្បាប់របស់សម្ព័ន្ធកូសេកាំ
- កញ្ញា ការ៉ែន ហ្វ្រីន ជាទីប្រឹក្សាដែលជ្រើសរើសដោយសម្ព័ន្ធអង្គការកូសេកាំ ដើម្បីព្រាងសៀវភៅយោងរបស់ *គកស* ។
- លោក ចន វីហ្គេន ទីប្រឹក្សាបច្ចេកទេសរបស់គម្រោងសិតកាំ ។
- ក្រុមការងារកូសេកាំ ក្រោមការណែនាំរបស់ លោក ទូន វិចិត្រ ប្រធានសម្ព័ន្ធអង្គការកូសេកាំ ។
- គម្រោង **CTIP** របស់អង្គការមូលនិធិអាស៊ី ។
- កិច្ចប្រជុំក្រៅផ្លូវការរបស់ក្រុមការងារជួយសង្គ្រោះជនរងគ្រោះ ដោយមានការចូលរួមពីសំណាក់ភ្នាក់ងារជាតិ និងអន្តរជាតិក្នុងឆ្នាំ ២០០៦-២០០៧ ។
- សិក្ខាកាមនៃសិក្ខាសាលាប្រឹក្សាយោបល់ទាំងបីខាងលើអំពី *គកស* ដែល ធ្វើឡើងក្នុងឆ្នាំ ២០០៨ ។

## តើមូលហេតុអ្វីដែលបង្កើតឱ្យមានសៀវភៅណែនាំនេះ ?

សិតកាំ ជាគម្រោងមួយដែលធ្វើកិច្ចសហប្រតិបត្តិការយ៉ាងជិតស្និទ្ធជាមួយនឹងនាយកដ្ឋានសុខមាលភាពកុមារនៃក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ដោយមានការគាំទ្រពីគម្រោងប្រឆាំងនឹងការជួញដូរមនុស្សរបស់មូលនិធិអាស៊ី សម្ព័ន្ធអង្គការចាប់ដៃ មូលនិធិកុមារអង្គការសហប្រជាជាតិ (UNICEF) អង្គការអន្តរជាតិសម្រាប់ទេសន្តរប្រវេសន៍ (IOM) និងអង្គការផ្សេងៗទៀតបានរកឃើញនូវដំណោះស្រាយប្រសើរជាងមុនសម្រាប់ជួយដល់ជនរងគ្រោះពីការកេងប្រវ័ញ្ច និងអំពើហិង្សានាពេលបច្ចុប្បន្ននេះ ។ លទ្ធផលសរុបនៃការរកឃើញនេះ គឺការបង្កើតឱ្យមានប្រព័ន្ធនៃការគ្រប់គ្រងករណីដោយកិច្ចសម្របសម្រួល (គកស) មួយ ដែលថ្នាក់ជាតិ(មជ្ឈិម)ជាអ្នករៀបចំចាត់ចែង និងថ្នាក់ខេត្ត-ក្រុងជាអ្នកអនុវត្ត ។ យុទ្ធសាស្ត្រនៃប្រព័ន្ធនេះ បានផ្ដោតការយកចិត្តទុកដាក់ជាមូលដ្ឋានទៅលើឧត្ដមប្រយោជន៍របស់អតិថិជន ។ ប្រព័ន្ធ *គកស* ទាមទារឱ្យមានការអនុវត្តសាកល្បងជាមុនសិន មុននឹងឱ្យប្រព័ន្ធនេះក្លាយទៅជាប្រព័ន្ធបញ្ជាបមួយមានកម្រិតថ្នាក់ជាតិ ។ ប្រព័ន្ធនេះត្រូវរៀបរៀងចេញជាសៀវភៅណែនាំមួយ ដែលមានទម្រង់ខ្លី ហើយជាសៀវភៅមួយសម្រាប់ជាឧបករណ៍មគ្គុទេសក៍ជួយដល់អ្នករៀបចំគោលនយោបាយ អ្នកផ្ដល់សេវាកម្ម និងភ្នាក់ងារផ្សេងៗទៀតដើម្បីឱ្យពួកគេទទួលបាននូវការគិតគូរបានល្អឿនចំពោះវិធីនៃការបញ្ជូនអតិថិជនឱ្យស្របតាមជំហានត្រឹមត្រូវ ។ ទោះជាយ៉ាងណាក៏ដោយ អ្នកជំនាញគួរតែស្រាវជ្រាវបន្ថែមក្នុងសៀវភៅណែនាំដែលមានទម្រង់ពិស្ដាររបស់ *គកស* (អាចទទួលយកបានពីកូសេកាំ) និងឯកសារជាក់លាក់ផ្សេងៗធ្វើឡើងដោយគម្រោង CTIP នៃអង្គការមូលនិធិអាស៊ី ។

**ការវិភាគបញ្ហា**

ជាទូទៅស្ថិតិអំពីការជួញដូរមនុស្សមានលក្ខណៈលំបាករក ហើយបើរកបានក៏មិនសូវជាមានជំនឿទុកចិត្តទៀតផង។ ទាមការសិក្សាឃើញថា ក្នុងចំណោមជនដែលត្រូវបានគេជួញដូរ គឺកុមារជាអ្នកងាយនឹងរងគ្រោះជាងគេ។ ទិន្នន័យដែលបានប្រមូលពីអង្គការអន្តរជាតិសម្រាប់ទេសន្តរប្រវេសន៍ (IOM) បានបង្ហាញថា ៩៦% នៃស្ត្រីដែលធ្វើមាតុភូមិនិវត្តន៍មកពីប្រទេសថៃ ពួកគេមានអាយុ ១៨ ឬក្រោម ១៨ឆ្នាំ ហើយ ៧% នៃក្មេងទាំងនេះគឺជាកុមារដែលមានអាយុពី ៦ឆ្នាំ ទៅ ១៣ឆ្នាំ។ ស្ថិតិនេះចង្អុលបង្ហាញថាសមាមាត្រដែលមានភាគរយខ្ពស់ក្នុងទិន្នន័យនៃការជួញដូរមនុស្សនេះគឺទាក់ទងទៅនឹងកុមារអាយុ ១៨ ឬក្រោម ១៨ឆ្នាំ។ លទ្ធផលនៃការស្រាវជ្រាវថ្មីៗមួយទៀតឱ្យដឹងថាមានកុមារសុំទាននៅតាមដងវិថីក្នុងទីក្រុងបាងកក។ នៅក្នុងឆ្នាំ ២០០០ តាមការប៉ាន់ប្រមាណមានកុមារប្រហែល ៦០នាក់ ដើរសុំទាន ហើយចំនួននេះមានការកើនឡើងរាប់រយនាក់ក្នុងឆ្នាំ ២០០៥ និងកើនរហូតទៅដល់តួលេខរាប់ពាន់ក្នុងឆ្នាំ ២០០៨ ដែលក្នុងនោះភាគច្រើននៃក្មេងគឺមកពីប្រទេសកម្ពុជា។

អង្គការក្រៅរដ្ឋាភិបាលដែលផ្តល់សេវាទៅដល់ជនរងគ្រោះដោយការជួញដូរ បានរាយការណ៍នៅក្នុងរបាយការណ៍ប្រចាំឆ្នាំរបស់ខ្លួនថា យ៉ាងហោចណាស់មានចំនួន ២០០នាក់ ដែលបានជួយសង្គ្រោះឱ្យរួចផុតពីអាជីវកម្មកេងប្រវ័ញ្ចផ្លូវភេទ ត្រូវបានផ្តល់ជម្រកទៅឱ្យជនរងគ្រោះក្រោមអាយុ។ តាមពិតតួលេខនេះមានចំនួនមិនស្មើនឹងតួលេខដែលយើងបានដឹងសូម្បីតែបន្តិច។ របាយការណ៍របស់ UNDP បានប៉ាន់ប្រមាណថា យ៉ាងហោចណាស់ក៏មានក្មេងស្រីប្រមាណ ២០០០នាក់ ដែលមានអាយុក្រោម ១៨ឆ្នាំ ចូលទៅបម្រើក្នុងឧស្សាហកម្មផ្លូវភេទជារៀងរាល់ឆ្នាំ។ ចំណែកឯច្បាប់ស្តីពីការបង្ក្រាប និងទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ ដែលត្រូវបានអនុម័តដោយរដ្ឋសភា ដើម្បីផ្តល់នូវឧបករណ៍ផ្នែកច្បាប់សម្រាប់ដោះស្រាយបញ្ហាអំពើហិង្សាក្នុងគ្រួសារ ប្រហែលជានឹងអាចជួយសម្រួលដល់ការចោទប្រកាន់ទោសដល់ឧក្រិដ្ឋជន នៅខណៈពេលដែលសមាជិកគ្រួសាររំលោភបំពានផ្លូវភេទលើកុមារ។ ប៉ុន្តែអំពើរំលោភនៅតែមានការកើនឡើងជាលំដាប់ក្នុងសង្គមកម្ពុជា មិនមែនចេះតែថាមានការកើនឡើងពីព្រោះវាកើនឡើងនោះទេ (គ្មានទិន្នន័យច្បាស់លាស់បញ្ជាក់ ពីព្រោះកង្វះនូវព័ត៌មានដំបូងសម្រាប់ប្រៀបធៀប) តែធាតុពិតគេទទួលស្គាល់ថា វាគឺជាបញ្ហា។ អង្គការពលកម្មអន្តរជាតិបានរាយការណ៍ផ្អែកលើមូលដ្ឋាននៃការសិក្សាថា ២/៣ នៃចំនួនកុមារមួយលានកន្លះ ដែលធ្វើការគេបានចំណាយពេលធ្វើការពីចន្លោះ ១៥ ទៅ ៣៤ម៉ោង ក្នុងមួយសប្តាហ៍។ កុមាររាប់រយនាក់បានធ្វើការដើម្បីជួយដោះស្រាយជីវភាពគ្រួសារ ដោយធ្វើការពេញម៉ោងនៅក្នុងស្រែអំបិល ឡូត៍នេសាទ ចំការកៅស៊ូ វាយបំបែកថ្ម ធ្វើក្បឿង រោងចក្រ និងការងារគ្រោះថ្នាក់ផ្សេងៗទៀត។ បុគ្គលិកធ្វើការងារសង្គមធ្វើការប៉ាន់ប្រមាណក្នុងរបាយការណ៍ដដែលថា មានកុមារអនាថាយ៉ាងហោចណាស់ ១០០០នាក់ នៅក្នុងទីក្រុងភ្នំពេញ។ អង្គការផ្សេងៗទៀត ប៉ាន់ប្រមាណថា ឥឡូវនេះតួលេខនេះមានចំនួនខ្ពស់ជាងមុន។ ទិន្នន័យដែលបានបង្ហាញខាងលើមិនបានឆ្លុះបញ្ចាំងនូវស្ថិតិពិតប្រាកដដែលអាចទុកចិត្តបាននៃស្ថានភាពរបស់បុរស-ស្ត្រី និងកុមារដែលត្រូវបានគេកេងប្រវ័ញ្ច រំលោភបំពានប្រមាថធ្វើបាប ឬព្រងើយកន្តើយនោះទេ។ ទិន្នន័យទាំងនេះគ្រាន់តែជាការពិពណ៌នានូវហេតុការណ៍ ដែលបានកើតឡើងចំពោះពួកគេប៉ុណ្ណោះ។ ទោះបីជាយ៉ាងណាក៏ដោយ វាមានការបញ្ជាក់យ៉ាងច្បាស់តាមរយៈទិន្នន័យពីអ្នកធ្វើការជាមួយនឹងជនរងគ្រោះនៅក្នុងប្រទេសថា មានករណីធ្ងន់ធ្ងរជាច្រើនដែលគេមិនបានទទួលការគាំពារនូវអ្វីដែលគេត្រូវការ។ ហេតុអ្វីបានជាពួកគេមិនអាចទទួលបានតាមតម្រូវការ ? តើគ្មានការខិតខំប្រឹងប្រែងពីសង្គមស៊ីវិល និងរដ្ឋាភិបាលដើម្បីជួយពួកគេឬ ? ជាការពិតអ្វីដែលផ្ទុយពីសំនួរនេះគឺជាចម្លើយដែលត្រឹមត្រូវ។ មានអង្គការក្រៅរដ្ឋាភិបាលជាតិ និងអន្តរជាតិជាច្រើនមានការព្រួយបារម្ភចំពោះបញ្ហានេះ ហើយគេបានធ្វើអ្វីដែលពួកគេអាចធ្វើបានដើម្បីការពារជនរងគ្រោះ។ ប៉ុន្តែការខិតខំប្រឹងប្រែងទាំងនេះមិនបានជាប់លាប់មិនមានការគាំទ្រមិនមាន

ការរៀបចំបានល្អ ហើយមិនសូវមានប្រសិទ្ធភាព។ បើទោះជាមានគម្រោងផែនការ និងគោលនយោបាយថ្នាក់ជាតិជាច្រើនក៏ដោយ ក៏នៅតែមិនទាន់មានវិធីសាស្ត្រល្អសម្រាប់ការពារជនរងគ្រោះឡើយ។ ដូច្នេះយន្តការដែលនឹងនាំមកនូវ និងរក្សារបៀបរបបធ្វើអន្តរាគមន៍បន្តបានក្នុងពេលបច្ចុប្បន្ននេះ គឺត្រូវតែជាយន្តការមួយដែលមានកម្រិតថ្នាក់ជាតិ និងជាយន្តការមួយ ដែលគួរតែអាចទាក់ទាញបាននូវការធ្វើអន្តរាគមន៍ក្នុងកម្រិតមួយទូលំទូលាយ។ យ៉ាងណាក៏ដោយ ដូចបានជ្រាបទាំងអស់គ្នាហើយថា យន្តការនេះអាចដំណើរការទៅបាន លុះត្រាតែតួអង្គសំខាន់ៗ ជាពិសេសរដ្ឋាភិបាលគេទទួលស្គាល់យន្តការនេះ។ នៅក្នុងករណីនេះ យើងមិនបានសំឡឹងមើលទៅលើការបង្កើតគណៈកម្មការ ឬក្រុមប្រឹក្សា ឬក្រុមការងារធ្វើជាអ្នកផ្ដល់ប្រឹក្សាលើទិសដៅនៃការអនុវត្តនោះទេ។ គណៈកម្មការនេះ តាមពិតវាមានស្រាប់ហើយដូចជាក្រុមការងារថ្នាក់ជាតិប្រឆាំងនឹងការជួញដូរមនុស្ស គឺមានចំណងទាក់ទងគ្នាចំពោះការងារនេះ ប៉ុន្តែគណៈកម្មការនេះវាក៏មិនមែនជាយន្តការដែលយើងកំពុងស្វែងរក ហើយវាក៏មិនមែនជាយន្តការដែលអាចរក្សាបាននូវការអន្តរាគមន៍បច្ចុប្បន្នបន្តទៀតនោះដែរ។ យន្តការដែលត្រូវការគឺយន្តការមួយដែលមានឥទ្ធិពលក្នុងការធ្វើសកម្មភាព និងជាយន្តការមួយដែលអាចទាក់ទាញបណ្ដាអង្គការ និងទីភ្នាក់ងារជួយជនរងគ្រោះទាំងនោះមកចូលរួមពាក់ព័ន្ធក្នុងសកម្មភាពជួយជនរងគ្រោះ។ ឆ្លើយតបចំពោះបញ្ហានេះនឹងត្រូវបានបកស្រាយ ដោយដំណើរការនៃប្រព័ន្ធ *គកស* ។

## វិធីសាស្ត្ររួមនៃប្រព័ន្ធ *គកស*

វិធីសាស្ត្ររួមនៃការគ្រប់គ្រងករណីដោយកិច្ចសម្របសម្រួល (គកស) ដែលបានលើកឡើងនៅទីនេះត្រូវបានច្របាច់បញ្ចូលគ្នានូវវិធីសាស្ត្រ ៥យ៉ាង ហើយវិធីសាស្ត្រទាំង ៥ នេះមានលក្ខណៈខុសប្លែកពីវិធីសាស្ត្រដទៃ។ ការគ្រប់គ្រងករណីដោយកិច្ចសម្របសម្រួលមានវិធីសាស្ត្ររបស់វាដូចតទៅ : ផ្សារភ្ជាប់ការគ្រប់គ្រងករណីអតិថិជនម្នាក់ៗទៅនឹងការចុះបញ្ជីជនរងគ្រោះដោយការជួញដូរតាមប្រព័ន្ធថ្នាក់ជាតិ ការសម្របសម្រួលជាលក្ខណៈប្រព័ន្ធនៃការបញ្ជូនអតិថិជន ការផ្ដួចផ្ដើម ការវាយតម្លៃតម្រូវការសង្គមរបស់អតិថិជនសម្រាប់ករណីណាដែលមានភាពស្មុគស្មាញ ប្រើវិធីសាស្ត្រសន្និសីទករណីក្នុងការវាយតម្លៃនៅក្នុងកម្រិតថ្នាក់ខេត្ត និងការរៀបចំការស្ដានីតិសម្បទា និងធ្វើសមាហរណកម្មជនរងគ្រោះដោយការជួញដូរទាំងនោះទៅក្នុងតំបន់។ វិធីសាស្ត្រនេះបានផ្ដល់ឧត្ដមប្រយោជន៍ដល់ពួកគេ (មិនមែនជាទីកន្លែងដែលផ្ដល់លក្ខណៈងាយស្រួលដល់អ្នកផ្ដល់សេវានោះទេ)។ វិធីសាស្ត្រទាំងនេះ ត្រូវបានអនុវត្តខ្លះហើយនៅតំបន់មួយចំនួនក្នុងប្រទេសកម្ពុជា លើកលែងតែប្រព័ន្ធចុះបញ្ជីប៉ុណ្ណោះ ដែលមិនទាន់មានប្រព័ន្ធសម្របសម្រួល។ គុណសម្បត្តិចំបងនៃការបង្កើតប្រព័ន្ធនេះគឺបានបន្តរក្សាបាននូវឧត្ដមប្រយោជន៍អតិថិជន និងមានបទដ្ឋានមួយច្បាស់លាស់ក្នុងការផ្ដល់នូវសេវាផ្សេងៗដល់ជនរងគ្រោះ។ ប្រព័ន្ធនេះនឹងធ្វើឱ្យមានការផ្ដល់នូវសេវានៃការថែទាំ តាមរយៈដំណោះស្រាយនៅក្រៅមណ្ឌល ឬនៅក្នុងមណ្ឌល ការផ្ដល់ជំនាញសង្គម ការគាំពារផ្នែកច្បាប់ ការផ្ដល់អំណាចសង្គម និងនិរន្តភាពខ្លួនឯងតាមរយៈការសិក្សាបំណិនជីវិត ការបណ្ដុះបណ្ដាលជំនាញវិជ្ជាជីវៈ និងការលើកទឹកចិត្តឱ្យប្រកបអាជីវកម្មខ្នាតតូចដោយមានប្រសិទ្ធភាព។

# ប្រព័ន្ធទំនាក់ទំនងការងារ



## ការិយាល័យ *គកស* ខេត្ត

ការិយាល័យខេត្ត ដែលមានទីតាំងនៅមន្ទីសង្គមកិច្ច អតីតយុវជន និងយុវនីតិសម្បទា គឺជាផ្នែកសម្របសម្រួលយ៉ាងសំខាន់នៃប្រព័ន្ធ *គកស*។ ការិយាល័យនេះនឹងមានបុគ្គលិកម្នាក់មកពីមន្ទីរសង្គមកិច្ច បុគ្គលិកសង្គមម្នាក់មកពីគម្រោងសិតកាំ ដើរតួនាទីជាអ្នកសម្របសម្រួលថ្នាក់ខេត្ត និងលេខាធិការម្នាក់ទៀត។ ការិយាល័យនេះនឹងសម្របសម្រួលគ្រប់ជំហាននៃដំណើរការដោយចាប់តាំងពីការចុះបញ្ជី ការវាយតម្លៃ ការគ្រប់គ្រងករណីអតិថិជន ការបញ្ជូនអតិថិជន ការធ្វើសមាហរណកម្ម និងការតាមដាន បើសិនដំណើរការនេះស្ថិតនៅក្នុងខេត្តរបស់ពួកគេ។ នៅក្នុងករណីដែលដំណើរការ ឬការធ្វើសមាហរណកម្មត្រូវធ្វើនៅក្នុងខេត្ត ឬក្រុងផ្សេងទៀត ការិយាល័យខេត្តនឹងត្រូវផ្ទេរករណីនេះមកឱ្យការិយាល័យកណ្តាលនៅក្រុងភ្នំពេញ ដើម្បីសម្របសម្រួលការបញ្ជូនបន្តទៅកាន់ទីតាំងគោលដៅ។ ដូច្នេះការិយាល័យខេត្ត មានតួនាទីណែនាំអតិថិជនពីដំណើរការតាមជំហាននៃប្រព័ន្ធ *គកស*។ ការិយាល័យខេត្តជាអ្នករៀបចំការវាយតម្លៃពីតម្រូវការសង្គម និងការវាយតម្លៃផ្សេងទៀត ហើយក្នុងករណីមានភាពស្មុគស្មាញ ការវាយតម្លៃនេះនឹងត្រូវធ្វើជាលក្ខណៈសន្និសីទករណី ក្នុងលក្ខខណ្ឌនេះ ក្រុមអ្នកជំនាញដែលពាក់ព័ន្ធនឹងត្រូវចូលរួមធ្វើការវាយតម្លៃអំពីមូលដ្ឋាននៃតម្រូវការសង្គម និងចូលរួមពិនិត្យមើលតម្រូវការផ្សេងៗដែលអាចជួយពួកគេបានដោយឈរលើមូលដ្ឋានគិតគូរពីឧត្តមប្រយោជន៍ជនរងគ្រោះ។ ការិយាល័យខេត្តនឹងធ្វើការណែនាំការវាយតម្លៃតម្រូវការសង្គម និងធ្វើសន្និសីទករណីអតិថិជន រួចបញ្ជូនអតិថិជនទៅកន្លែងផ្តល់សេវាដែលសមស្រប ឬបញ្ជូនទៅកាន់ភ្នាក់ងារគាំពារជនរងគ្រោះឱ្យចំគោលដៅអតិថិជន។ ការិយាល័យខេត្តនឹងធ្វើការពិគ្រោះយោបល់ជាមួយនិង *ប្រធានផ្នែកសម្របសម្រួលការងារអង្គការជាដៃគូ* របស់គម្រោងសិតកាំ ដើម្បីគណនាតម្លៃដែលភ្ជាប់ជាមួយនឹងសេវាដែលត្រូវផ្តល់ និងរៀបចំធ្វើ សំណើថវិកា។ សំណើថវិកានេះនឹងត្រូវដាក់ទៅឱ្យគម្រោងសិតកាំ ដើម្បីសុំការយល់ព្រម។

## គណៈកម្មការធនធានមូលដ្ឋាននៃ *គកស*

គណៈកម្មការធនធានមូលដ្ឋាន (គធម) នឹងត្រូវបង្កើតឡើង ឬគណៈគ្រប់គ្រងដែលមានស្រាប់នឹងត្រូវជ្រើសតាំងឡើងដើម្បីទទួលខុសត្រូវលើការងាររបស់គណៈកម្មការ *គធម* នេះនៅក្នុងខេត្ត ឬក្រុងដែល*គកស* ត្រូវបានដាក់ឱ្យអនុវត្ត។ *គធម* នឹងដើរតួនាទីដូចជាគណៈគ្រប់គ្រងមូលដ្ឋានដើម្បីសម្របសម្រួលដំណើរការការិយាល័យខេត្ត។ គណកម្មការនេះនឹងជាគណៈគ្រប់គ្រងមួយ ដែលអាចធ្វើការរៀបចំរចនាសម្ព័ន្ធជាមួយនឹងភ្នាក់ងារអាជ្ញាធរមូលដ្ឋាន អង្គការសង្គមស៊ីវិល ស្ថាប័នសុខមាលភាព និងអប់រំ-ល-ដើម្បីជួយទៅដល់អតិថិជន។ ឧទាហរណ៍ : អតិថិជនម្នាក់ដែលមានអាយុត្រូវចូលរៀន *គធម* នឹងធ្វើការបញ្ជូនកុមារនោះឱ្យទៅកាន់សាលារដ្ឋ។ ឧទាហរណ៍មួយទៀត អតិថិជនដែលត្រូវការថ្នាំសង្កូវ *គធម* នឹងនាំពួកគេទៅព្យាបាល ឬបញ្ជូនឱ្យពួកគេឱ្យទៅជួបនឹងវិជ្ជបណ្ឌិត។ នៅក្នុងករណីដែលអតិថិជនចង់ត្រឡប់ទៅស្នាក់អាស្រ័យនៅផ្ទះវិញ ហើយត្រូវការជំនាញដើម្បីបង្កើតចំនូលនោះ *គធម* នឹងរៀបចំរចនាសម្ព័ន្ធជំនួយសម្រាប់ជួយពួកគេ។ *គធម* នឹងប្រើប្រាស់លក្ខណៈវិនិច្ឆ័យដែលធ្វើឡើងដោយគម្រោងសាកល្បងចាត់តាំងភ្នាក់ងារអ្នកផ្តល់សេវានៅក្នុងតំបន់សាកល្បងគម្រោងតាមសេចក្តីត្រូវការរបស់អតិថិជន។ *គធម* នឹងធ្វើជាតំណាងឱ្យអាជ្ញាធរខេត្តក្នុងការផ្តល់នូវប្រឹក្សាយោបល់ដល់ការិយាល័យខេត្តលើការអនុវត្តគម្រោងសាកល្បងនេះ។

## ក្រុមអ្នកត្រួតពិនិត្យនៃ *គកស*

គ្រប់ដំណើរការដើម្បីជួយដល់ជនរងគ្រោះ តម្រូវឱ្យមានការត្រួតពិនិត្យ ហើយការត្រួតពិនិត្យនេះមិនមែនមានតែនៅក្នុងបរិបទនៃគម្រោងសិតកាំ ដែលមានកាតព្វកិច្ចចំពោះម្ចាស់ជំនួយសហគមន៍អ៊ឺរ៉ុបនោះទេ ប៉ុន្តែវាក៏ជាមធ្យោបាយដើម្បីធានានូវឧត្តមប្រយោជន៍របស់អតិថិជនផងដែរ។ ក្រុមអ្នកត្រួតពិនិត្យនៃ *គកស* នឹងមានបុគ្គលិកមកពីមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងគម្រោងសិតកាំ មកពីការិយាល័យថ្នាក់កណ្តាល (ក្រសួង និងគម្រោងសិតកាំផ្នែកសម្របសម្រួលការងារអង្គការជាដៃគូ) ដោយមានការចូលរួមពីសមាជិករបស់ក្រុមការងារមូលដ្ឋាន (មន្ទីរខេត្ត និងអង្គការក្រៅរដ្ឋាភិបាលដែលបានទទួលស្គាល់ដោយ*គកស*)។ ក្រុមការងារការិយាល័យកណ្តាលនឹងសម្របសម្រួលទៅលើសកម្មភាពត្រួតពិនិត្យ និងណែនាំឬបណ្តុះបណ្តាលក្រុមការងារខេត្តសម្រាប់សកម្មភាពត្រួតពិនិត្យនេះ។

## ក្រុមអ្នកប្រឹក្សាយោបល់នៃ *គកស*

ក្រុមអ្នកប្រឹក្សាយោបល់នៃគកស (***កយ***) នឹងបង្កើតឡើង ដោយមានការចូលរួមពីភ្នាក់ងារពាក់ព័ន្ធសំខាន់ៗ (រួមបញ្ចូលទាំងមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា) ដែលនឹងត្រូវចាត់ចែងប្រតិបត្តិប្រព័ន្ធ *គកស* នៅក្នុងខេត្តសាកល្បង។ ផ្នែកសម្របសម្រួលបច្ចេកទេសនៃគម្រោងសិតកាំ នឹងរៀបចំឯកសារ និងរបាយការណ៍ទៅឱ្យ ***កយ***។ ***កយ*** នឹងធ្វើការវាយតម្លៃលទ្ធផលទាំងនោះ បើសិនជាមានតម្រូវការចំបាច់ក្នុងការផ្តល់នូវអនុសាសន៍ឱ្យមានសកម្មភាពសមស្របសម្រាប់គម្រោងសិតកាំនោះ។

## ដំណាក់កាលទាំង ១០ នៃដំណើការ *គកស*

### *ដំណាក់កាលទី១ : ការផ្តល់អត្តសញ្ញាណមុនពេលមានសកម្មភាពផ្សេងៗ*

យើងត្រូវពិនិត្យនូវអត្តសញ្ញាណជនរងគ្រោះជាមុនសិន ឧទាហរណ៍ : តាមរយៈការឆ្មក់ចូលរបស់កំលាំងប៉ូលីសទៅលើផ្ទះបន ឬតាមរយៈមុខសញ្ញាផ្សេងទៀត (ទូរស័ព្ទសង្គ្រោះបន្ទាន់អ្នកជិតខាងជាដើម)។ ប្រព័ន្ធនេះមានគោលដៅអនុវត្តទៅលើជនរងគ្រោះដោយការជួញដូរ ជនចំណាកស្រុកដោយខុសច្បាប់ ជនរងគ្រោះនៃអំពើហិង្សាក្នុងគ្រួសារ ជនរងគ្រោះនៃការរំលោភបំពានផ្លូវភេទ និងករណីផ្សេងៗទៀត ។

### *ដំណាក់កាលទី២ : ការចុះបញ្ជីការ*

នៅពេលដែលជនរងគ្រោះត្រូវបានកំណត់អត្តសញ្ញាណរួចហើយ ពួកគេនឹងត្រូវបានផ្តល់នូវជំរកបណ្តោះអាសន្ន បើសិនជាពួកគេត្រូវការ។ ករណីនេះគួរតែត្រូវបានចុះបញ្ជីភ្លាមៗនៅក្នុងប្រព័ន្ធគ្រប់គ្រងទិន្នន័យរបស់ការិយាល័យកណ្តាល *គកស*។ សកម្មភាពផ្សេងទៀត ឬការបញ្ជូនអតិថិជន គួរតែត្រូវបានរាយការណ៍ដូចនេះ។ បញ្ជីត្រូវតែធ្វើបច្ចុប្បន្នភាព ដើម្បីឱ្យមានភាពងាយស្រួលក្នុងការតាមដានដោយអ្នកជំនាញលើករណីរបស់អតិថិជន។ ធ្វើដូចនេះកុំឱ្យមានឱកាសណាមួយ បណ្តាលឱ្យបាត់ព័ត៌មានរបស់អតិថិជនចេញពីប្រព័ន្ធ។ អត្តសញ្ញាណ និងភាពសម្ងាត់របស់អតិថិជននឹងត្រូវរក្សាទុកប្រកបដោយសុវត្ថិភាព។

### *ដំណាក់កាលទី៣ : ការវាយតម្លៃតម្រូវការសង្គម*

ការវាយតម្លៃតម្រូវការសង្គមមួយគួរតែធ្វើដោយអ្នកជំនាញការផ្នែកសង្គម និងរាយការណ៍ករណីទៅឱ្យការិយាល័យខេត្តយ៉ាងឆាប់បំផុតតាមដែលអាចធ្វើបាន យ៉ាងយូរបំផុតរយៈពេល ២សប្តាហ៍។ របាយការណ៍នេះនឹងត្រូវភ្ជាប់នូវយោបល់ណែនាំប្រសិនបើករណីមួយនេះតម្រូវឱ្យមានការផ្តួចផ្តើមធ្វើសន្និសីទករណី និងបញ្ជាក់ពីអ្នកជំនាញដែលបានចូលរួមធ្វើប្រឹក្សាយោបល់នោះ។ ការិយាល័យខេត្តនឹងត្រូវពិនិត្យឡើងវិញនូវរបាយការណ៍ករណីភ្លាម១ ហើយអញ្ជើញអ្នកជំនាញដែលពាក់ព័ន្ធសម្រាប់ការធ្វើសន្និសីទករណីទាំងអស់គ្នាចូលរួម។

### *ដំណាក់កាលទី៤ : ការផ្តួចផ្តើមសន្និសីទករណី*

សន្និសីទករណីដែលមានការចូលរួមពីអ្នកជំនាញ និងមន្ត្រីពាក់ព័ន្ធត្រូវបានផ្តួចផ្តើមធ្វើឡើងដើម្បីពិភាក្សាអំពីតម្រូវការសម្រាប់អតិថិជនថាតើសេវាអ្វីដែលត្រូវផ្តល់ ហើយស្ថិតក្នុងដំណាក់កាលណានៃដំណើរការនៃការព្យាបាល ការស្តារនីតិសម្បទា និងការធ្វើសមាហរណកម្ម។ អ្នកជំនាញទាំងនេះមិនត្រឹមតែជាអ្នកមានបទពិសោធន៍ក្នុងការងាររបស់គេប៉ុណ្ណោះទេ ប៉ុន្តែជាអ្នកដែលមានទឹកចិត្តជួយជនរងគ្រោះទៀតផង។ ក្រោយពីទទួលបានដំណឹងភ្លាម១នោះពួកគេ ត្រូវតែត្រៀមខ្លួនរួចជាស្រេច ដើម្បីការចូលរួម (ជនរងគ្រោះមិនអាចរង់ចាំរយៈពេលយូរពេកទេ មុនពេលដែលយើងដឹងថា តើមានរឿងអ្វីកើតឡើងចំពោះពួកគេនោះ)។ អ្នកជំនាញដែលត្រូវចូលរួម គឺអាស្រ័យទៅលើករណីដែលនឹងចង្អុលបង្ហាញ តាមរយៈការវាយតម្លៃរបាយការណ៍ករណីរៀបចំដោយអ្នកជំនាញ (ដូចជាអ្នកធ្វើការងារសង្គមជាដើម)។ ឧទាហរណ៍ : បើសិនជាមានសេចក្តីរាយការណ៍អំពីករណីរបួសផ្លូវចិត្ត និងសង្គម អ្នកចិត្តវិទ្យាគួរណាស់តែចូលរួមក្នុងសន្និសីទករណីនេះ ឬក្នុងករណីមួយទៀតដែលជនរងគ្រោះ ចង់ធ្វើជាកស្មិរណសាក្សីនៅក្នុងតុលាការ អ្នកដែលមានសមត្ថកិច្ចក្នុងការចូលរួមនេះ គឺប៉ូលីស។ នៅពេលមានករណីដែលមានបញ្ហាទាក់ទងទៅនឹងសុខភាព អ្នកជំនាញសុខភាពត្រូវការចាំបាច់ណាស់ក្នុងការចូលរួម។ ទន្ទឹមនឹងនេះ អ្នកជំនាញផ្នែកអប់រំ ក៏តម្រូវឱ្យមានស្របពេលដែលបញ្ហាផ្នែកសិក្សា ឬបណ្តុះបណ្តាលត្រូវការនោះ។ អ្នកធ្វើការងារសង្គមតែងតែត្រូវការជានិច្ច ហើយអ្នកតំណាងរបស់អ្នកផ្តល់សេវា (ទីភ្នាក់ងាររដ្ឋាភិបាល ឬអង្គការក្រៅរដ្ឋាភិបាលផ្សេង១) ក៏ទាមទារឱ្យមានផងដែរ ដើម្បីឱ្យយោបល់អំពីសេវាផ្សេង១ដែលអតិថិជនត្រូវការដូចជា ការស្តារនីតិសម្បទា និងការធ្វើសមាហរណកម្មទៅក្នុងក្រុមគ្រួសារ ឬសហគមន៍ ឬសង្គមឡើងវិញ។ ការិយាល័យខេត្តអាចសម្រេចរៀបចំគំនិតផ្តួចផ្តើមសន្និសីទករណីនៅក្នុងដំណាក់កាលទាំងនោះ ឧទាហរណ៍ : ដំបូងអំពីទិដ្ឋភាពសុខមាលភាពសង្គម ហើយបន្ទាប់មកទិដ្ឋភាពច្បាប់ ឬការបណ្តុះបណ្តាល។ ការិយាល័យ *ពកស* នឹងក្លាយជាប្រធាននៃសន្និសីទករណី ហើយនិងត្រូវប្រឹក្សាជាមួយអតិថិជនអំពីសកម្មភាព និងទំហំនៃការណែនាំសម្រាប់ការព្យាបាល ការស្តារនីតិសម្បទា និងការធ្វើសមាហរណកម្មឡើងវិញ។ បន្ទាប់មកទៀតការិយាល័យនឹងធ្វើការសម្រេចចិត្តចុងក្រោយអំពីសកម្មភាពដែលត្រូវធ្វើ។ ការធ្វើសេចក្តីសម្រេចចិត្តនេះមួយចំណែកអាចធ្វើទៅលើថាតើស្ថាប័នភ្នាក់ងារ ឬអង្គការក្រៅរដ្ឋាភិបាលណាមួយដែលជាអ្នកផ្តល់សេវាដល់ជនរងគ្រោះ។

### *ដំណាក់កាលទី៥ : ផែនការករណីជនរងគ្រោះ*

ការិយាល័យខេត្តនឹងរៀបចំព្រាងផែនការសម្រាប់ការព្យាបាល ការស្តារនីតិសម្បទា និងការធ្វើសមាហរណកម្មឡើងវិញដោយមានការបញ្ជាក់ពីពេលវេលា អង្គការអ្នកផ្តល់សេវាដែលបានជ្រើសរើស និងចំនួនថវិកាដែលត្រូវការដើម្បីទ្រទ្រង់ ការចំណាយរបស់ជនរងគ្រោះ។ ផែនការករណីនេះនឹងជាសេចក្តីព្រាង ហើយនឹងត្រូវបានកែលំអនៅពេលដែលដំណើរការនៃការព្យាបាល

ការស្តារនីតិសម្បទា និងការធ្វើសមាហរណកម្មឡើងវិញចាំបាច់ទោះនៅពេលណាក៏ដោយ ឬទីណាក៏ដោយ ដើម្បីបំពេញនូវឧត្តមប្រយោជន៍របស់អតិថិជននោះ។ ការិយាល័យខេត្តនឹងតាមដានលើករណីនេះ ហើយបន្តធ្វើបច្ចុប្បន្នភាពប្រព័ន្ធចុះបញ្ជីកណ្តាល។ ការជ្រើសតាំងអ្នកគ្រប់គ្រងករណីគឺវាអាស្រ័យទៅលើ ឬក៏អាស្រ័យទៅនឹងសំណើរបស់អតិថិជន។ អ្នកធ្វើការលើករណី ឬតាមការស្នើរបស់អ្នកផ្តល់សេវាអាចធ្វើសន្និសីទករណីតាមដាន ដើម្បីពិភាក្សាលើដំណើរការ ឬការផ្លាស់ប្តូរផែនការនេះ។ ការកោះសន្និសីទករណីតាមដាននេះអាចធ្វើទៅបាននៅក្នុងខេត្តដដែល ហើយអ្នកចូលរួមវាយតម្លៃដដែល ដូចសន្និសីទករណីដំបូង ឬនៅក្នុងទីតាំងបច្ចុប្បន្ននៃអតិថិជន ដោយអញ្ជើញអ្នកជំនាញពាក់ព័ន្ធផ្សេងទៀតចូលរួម។ ការិយាល័យខេត្តនឹងសម្រេចបិទករណីដោយមានការប្រឹក្សាយោបល់ជាមួយនឹងអតិថិជន និងអ្នកផ្តល់សេវា និងជូនដំណឹងទៅអ្នកចុះបញ្ជីកណ្តាល។

***ដំណាក់កាលទី៦ : ការផ្ទេរ***

កាផ្ទេរករណីទៅអ្នកផ្តល់សេវា នឹងត្រូវធ្វើឡើងដោយផ្អែកលើផែនការករណីអតិថិជន ដោយធ្វើការពិគ្រោះជាមួយអតិថិជនតើសេវាអ្វីខ្លះដែលគេត្រូវការ។ អ្នកផ្តល់សេវានឹងត្រូវកំណត់ដោយ *គគម* ដោយប្រើប្រាស់លក្ខណៈវិនិច្ឆ័យដែលមានគុណភាពដើម្បីឧត្តមប្រយោជន៍អតិថិជន។ ទោះបីជាយ៉ាងណា ប្រសិទ្ធភាពនៃការចំណាយសេវាទាំងនោះ ក៏ត្រូវការយកមកពិចារណាដែរ។ សំខាន់ត្រូវធ្វើការវាយតម្លៃថាតើកន្លែងណាដែលអាចផ្តល់សេវាល្អបំផុត។ ឧទាហរណ៍ សេវានៃការព្យាបាល ត្រូវការជាបន្ទាន់នៅនឹងកន្លែងក្នុងពេលនោះ ប៉ុន្តែពួកគេត្រូវការសេវាជំនាញបណ្តុះបណ្តាលវិជ្ជាជីវៈ ដែលត្រូវធ្វើនៅទីកន្លែងកំណើតរបស់គេ ដូច្នេះគេត្រូវតែមានការសម្របសម្រួលនៃការធ្វើសមាហរណកម្មឡើងវិញ។ ការថែទាំក្នុងមណ្ឌល បើទោះជាបណ្តោះអាសន្នក្តីនឹងត្រូវបានពិចារណាថាជាមធ្យោបាយក្រោយបង្អស់នៃសកម្មភាពផ្ទេរ បើសិនជាគ្មានជម្រើសណាល្អប្រសើរជាងនេះទេនោះ។ ទោះជាយ៉ាងណាក៏ដោយអតិថិជនត្រូវទទួលការគាំពារក្នុងកំឡុងពេលព្យាបាល និងត្រូវសម្របខ្លួនទៅនឹងស្ថានភាពថ្មី មានន័យថាការថែទាំក្នុងមណ្ឌលមិនមានការលើកទឹកចិត្តឱ្យធ្វើនូវរាល់ករណីទាំងអស់នោះទេ ភ្នាក់ងារទទួលជនរងគ្រោះនឹងផ្តល់ការណែនាំអំពីសេវា ដែលមានទាំងអស់នោះដល់ពួកគេ។ ជាទូទៅភ្នាក់ងារទទួលជនរងគ្រោះទាំងនោះ មានតួនាទីដូចគ្នាទៅនឹងភ្នាក់ងារផ្តល់សេវាដែរ គឺមានតួនាទីផ្តល់ការថែទាំក្នុងមណ្ឌល។ ជាភ័ព្វសំណាង បើសិនបន្ទាប់ពីការសាកល្បងនូវជម្រើសផ្សេងៗសេវានៃការថែទាំក្នុងមណ្ឌលត្រូវបានគេទាមទារឱ្យរក្សាភ្នាក់ងារទទួលជនរងគ្រោះនៅដដែល ដើម្បីបន្តផ្តល់សេវាទាំងនោះ។ ក្នុងករណីគ្មានការផ្លាស់ប្តូរភ្នាក់ងារបែបនេះ ទំនាក់ទំនងរវាងភ្នាក់ងារទទួលជនរងគ្រោះ និងអតិថិជនត្រូវតែបន្តទៅទៀត។

***ដំណាក់កាលទី៧ : សេវាកម្ម***

ប្រភេទ និងសំណុំសេវានឹងមានលក្ខណៈផ្សេងៗគ្នាទៅតាមសេចក្តីត្រូវការរបស់អតិថិជន។ សេវាសង្គមតែងតែត្រូវការជានិច្ច ហើយចំពោះសេវាប្រឹក្សាវេជ្ជសាស្ត្រ និងចិត្តសាស្ត្រសង្គមក៏មានតម្រូវការដូចៗគ្នាដែរ។ សេវាផ្សេងៗត្រូវបានក្លាយទៅជាកម្មវត្ថុសម្រាប់ករណីនីមួយៗ ដូចជាជំនួយផ្នែកច្បាប់នៅក្នុងករណីដែលជនល្មើសត្រូវបានកាត់ទោស ផ្ទះកមណ្ឌលក្នុងករណីដែលគ្មានគ្រួសារ ឬមិត្តភ័ក្រដែលអាចជួយជនរងគ្រោះ ការអប់រំ ឬចូលសាលារៀនបណ្តុះបណ្តាល នៅក្នុងករណីដែលកុមារនោះស្ថិតនៅក្នុងអាយុសិក្សា និងជំនាញដើម្បីបង្កើតចំនូលក្នុងករណីដែលពួកគេត្រូវការ។ សេវាខ្លះមានរយៈពេលខ្លី ហើយខ្លះទៀតអាចនឹងបន្តជួយជនរងគ្រោះរហូតដល់ដំណាក់កាលធ្វើសមាហរណកម្ម ឧទាហរណ៍ប្រឹក្សាយោបល់អំពីការងារ ឬការផ្តល់ការប្រឹក្សារលើការរកស៊ី។

***ដំណាក់កាលទី៨ : ការធ្វើសមាហរណកម្ម និងការតាមដាន***

ការធ្វើសមាហរណកម្ម គឺជាដំណាក់កាលចុងក្រោយ ហើយត្រូវចាប់ផ្តើមនៅពេលណាដែលការព្យាបាល និងការត្រៀមខ្លួនសម្រាប់ជីវិតវិលត្រឡប់ចូលទៅក្នុងសង្គមវិញបានទទួលជោគជ័យទាំងស្រុង (ស្តារនីតិសម្បទា)។ ការគាំទ្រការធ្វើសមាហរណកម្ម គឺមានន័យថាជាការធ្វើឱ្យអតិថិជនបង្កើតឡើងវិញនូវជីវិតសេដ្ឋកិច្ចរបស់ពួកគេ។ រយៈពេលនៃការគាំទ្រផ្នែកសំភារ និងសង្គមនឹងមិនអាចធ្វើការប៉ាន់ប្រមាណបានទេ គឺវាក៏អាស្រ័យទៅនឹងកម្មវត្ថុរបស់ករណីនោះ។ យ៉ាងណាក៏ដោយសំខាន់បំផុតគេមិនត្រូវបញ្ឈប់ជំនួយរហ័សពេកទេ ពីព្រោះដំណាក់កាលនេះទាក់ទងនឹងការខិតខំប្រឹងប្រែងមុនៗទៅលើអតិថិជនដែលត្រូវធ្វើការពង្រឹងឡើងវិញនោះ។ នេះគឺជាហេតុផលមួយដែលនាំឱ្យមានដំណាក់កាលនៃការតាមដានទាមទារឱ្យធ្វើឡើងជាផ្នែក និងសំណុំនៃដំណើរការនៃការធ្វើសមាហរណកម្ម។ ក្នុងកំឡុងពេលធ្វើការតាមដាន មិនមែនតែស្ថានភាពរបស់អតិថិជន និងលក្ខខណ្ឌនៃការធ្វើសមាហរណកម្មត្រូវបានត្រួតពិនិត្យនោះទេ ប៉ុន្តែតម្រូវការនៃការគាំទ្រក៏ត្រូវវាយតម្លៃ និងផ្តល់ឱ្យផងដែរ។ គួរតែចាំក្នុងចិត្តថា នៅពាក់កណ្តាលឆ្នាំទី១ មានអតិថិជនធ្វើសមាហរណកម្មច្រើនណាស់ដែលបានលះបង់ និងបង្អោនតាមគំនាបសង្កត់របស់ជីវិតថ្មី តែជារឿយៗពួកគេទាំងនោះតែងតែធ្លាក់ចូលទៅក្នុងកលល្បិចរបស់អ្នកកេងប្រវ័ញ្ចម្តងទៀត។ ដូច្នេះការបន្តអប់រំសីលធម៌ និងការគាំទ្រផ្នែកសំភារ ពេលខ្លះនឹងត្រូវតែផ្តល់ឱ្យរហូតទាល់តែប្រាកដថាអតិថិជនអាចរស់នៅដោយខ្លួនបានដោយមិនចាំបាច់ជំនួយពីអ្នកជំនាញ។

***ដំណាក់កាលទី៩ : បិទករណី***

ដំណាក់កាលនេះជាតំណាក់កាលបញ្ចប់ករណី ហើយលុបចោលបញ្ជីឈ្មោះរបស់អតិថិជន។ ការបិទករណីអាចនឹងត្រូវបានតាមដានដោយភាពត្រឹមត្រូវមួយនៃដំណាក់កាលផ្សេងៗសម្រាប់ការអភិវឌ្ឍន៍ប្រព័ន្ធទៅថ្ងៃអនាគត។

***ដំណាក់កាលទី១០ : ការវាយតម្លៃ***

តំណាក់កាលទី១០នេះជាតំណាក់កាលវាយតម្លៃ ដែលត្រូវធ្វើឡើងដើម្បីរកឱ្យឃើញនូវកត្តាដែលនាំឱ្យជោគជ័យ និងទិដ្ឋភាពនៃប្រព័ន្ធដែលត្រូវកែលំអ និងផ្លាស់ប្តូរ។ នៅពេលដែលមានករណីភាគច្រើនអតិថិជនមិនជាប់ពាក់ព័ន្ធទៅនឹងដំណាក់កាលនេះទេ តែយ៉ាងណាក៏ដោយ វាប្រហែលជាមានអត្ថប្រយោជន៏ ប្រសិនបើអាចទទួលបាននូវគំនិតពីករណីផ្ទាល់របស់អតិថិជន ហើយផ្តល់គំនិតនេះទៅឱ្យអ្នកជំនាញដើម្បីគិតគូរ។

**គម្រោងសាកល្បង**

ប្រព័ន្ធ *គកស* គឺជាប្រព័ន្ធមួយថ្មីសម្រាប់ប្រទេសកម្ពុជា។ បើទោះជាមានការខិតខំប្រឹងប្រែងដូចគ្នាជាច្រើន ដែលទទួលបានជោគជ័យនៅក្នុងប្រទេសនានាក៏ដោយ ក៏ប្រសិទ្ធភាពនៃការប្រតិបត្តិប្រព័ន្ធនេះនៅកម្ពុជាក្នុងបរិបទមូលដ្ឋានស្ថិតក្នុងតំណាក់កាលនៃការស្រាវជ្រាវនៅឡើយ។ នៅទីបញ្ចប់គម្រោងសាកល្បងនៃប្រព័ន្ធនេះនឹងត្រូវធ្វើឡើងនៅខេត្ត ៣ និងក្រុង ១។ ការជ្រើសរើសខេត្តសម្រាប់សាកល្បង នឹងត្រូវធ្វើឡើងអាស្រ័យទៅលើស្ថានភាពក្នុងខេត្តទាំងនោះមានភាពមិនសូវស្មុគស្មាញ និងមានលក្ខណៈបើកចំហច្រើនសម្រាប់កិច្ចសហប្រតិបត្តិការជាងខេត្តដែលមានស្ថានភាពសាំញ៉ាំ និងក្រុងដ៏ធំមានភ្នាក់ងារច្រើន។ បន្ទាប់ពីប្រតិបត្តិការស្រាវជ្រាវរកព័ត៌មានពិត និងការធ្វើសិក្ខាសាលាមួយចំនួនរួចមកខេត្តបាត់ដំបង រួមទាំងខេត្តបន្ទាយមានជ័យ និងក្រុងប៉ៃលិនត្រូវបានជ្រើសរើសជាតំបន់សាកល្បងដំបូង។ គម្រោងសិតកាំ ដែលបានជំនួយហិរញ្ញវត្ថុពីសហគមន៍អ៊ឺរ៉ុប និងអង្គការ ICCO ហើយ

នឹងជំនួយផ្សេងៗទៀតសម្រាប់សាកល្បងគម្រោង ដែលផ្តល់ដោយ ANESVAD និង INTERVIDA ប្រព័ន្ធសាកល្បង *គកស* នឹងត្រូវសាកល្បងក្នុងកំឡុងឆ្នាំ ២០០៩ និង ២០១០។ គម្រោងសាកល្បងដំបូងនឹងត្រូវចាប់ផ្តើមនៅខែមករា ឆ្នាំ ២០០៩។ បន្ទាប់មកប្រហែលជា ៩ខែ មកទៀតគឺនៅខែតុលា ឆ្នាំ ២០០៩ ដដែល គម្រោងទី២ នឹងចាប់ផ្តើមនៅខេត្តផ្សេងទៀត ហើយរយៈពេល ៦ខែមកទៀត ការធ្វើពិសោធន៍នៃគម្រោងសាកល្បងនេះនឹងធ្វើនៅខេត្តទី ៣ ដំណាលគ្នា និងរាជធានីភ្នំពេញតែម្តង (ខែមេសា ឆ្នាំ២០១០)។ យើងសន្មតថាបន្ទាប់ពីការសាកល្បងទៅលើ ៤ខេត្ត-ក្រុង ប្រព័ន្ធនេះនឹងអាចបង្កើតទៅបាន និងមានលទ្ធភាពគ្រប់គ្រាន់សម្រាប់ពង្រីកទៅជាប្រព័ន្ធថ្នាក់ជាតិមួយ និងអាចអនុវត្តបានទូទាំងប្រទេស។

## យន្តការត្រួតពិនិត្យ

ប្រព័ន្ធ *គកស* និងដំណើរការរបស់វាទាមទារឱ្យមានការត្រួតពិនិត្យយ៉ាងជិតដិតបំផុតដោយភ្នាក់ងាររដ្ឋាភិបាលដែលពាក់ព័ន្ធ និងអង្គការសង្គមស៊ីវិលមួយ ចំនួន។ ចុងបញ្ចប់នេះការបង្កើតនូវក្រុមប្រឹក្សាពិគ្រោះយោបល់ *គកស* នឹងត្រូវស្នើឡើងដូចខាងក្រោម៖

**សេចក្តីណែនាំសម្រាប់ក្រុមប្រឹក្សាពិគ្រោះយោបល់នៃ *គកស* គោលដៅរបស់ប្រព័ន្ធ *គកស*** គឺដើម្បីធ្វើមជ្ឈការ និងបង្កើតឱ្យមានកិច្ចសម្របសម្រួលមួយប្រកបដោយវិជ្ជាជីវៈក្នុងការគាំទ្រដល់ជនរងគ្រោះ។

**ក្រុមគោលដៅ៖** គឺជនរងគ្រោះដោយការជួញដូរ ចំណាកស្រុកមិនប្រក្រតី ការកេងប្រវ័ញ្ច និងការរំលោភបំពាន គម្រោង *គកស* នឹងមានដំណើរការចាប់ពីឆ្នាំ ២០០៨ រហូតដល់ ២០១០។ ក្នុងកំឡុងឆ្នាំ ២០០៨ ខេត្ត និងក្រុងចំនួន ៤ ក្នុងប្រទេសកម្ពុជា នឹងត្រូវជ្រើសរើសសម្រាប់ធ្វើការសាកល្បង និងសម្របសម្រួលប្រព័ន្ធ *គកស*។ សមាជិកដែលបានស្នើសម្រាប់ក្រុមប្រឹក្សាយោបល់ *កយ* គឺ៖

| ភ្នាក់ងារ | ចំនួន | តួនាទី |
|---|---|---|
| អគ្គនាយករង ក្រសួងសង្គមកិច្ច | ១ | ប្រធាន |
| ផ្នែកសម្របសម្រួលបច្ចេកទេសនៃគម្រោងសិតកាំ | ១ | អនុប្រធាន |
| ការិយាល័យកណ្តាលនៃ*គកស* | ១ | លេខាធិការ |
| តំណាងមកពីក្រសួងមហាផ្ទៃ | ១ | សមាជិក |
| តំណាងមកពីក្រសួងយុត្តិធម៌ | ១ | សមាជិក |
| តំណាងមកពី *គសក* តាមខេត្ត | ១ | សមាជិក |
| អង្គការផ្តល់សេវាផ្នែកច្បាប់ | ១ | សមាជិក |
| អង្គការផ្តល់សេវាពិគ្រោះ | ១ | សមាជិក |
| អង្គការផ្តល់សេវាថែទាំតាមមណ្ឌល | ១ | សមាជិក |
| អង្គការផ្តល់សេវាថែទាំតាមផ្ទះ ឬថែទាំដោយឪពុក ម្តាយធម៌ | ១ | សមាជិក |
| ផ្នែកសម្របសម្រួលភ្នាក់ងារជាដៃគូនៃគម្រោងសិតកាំ | ១ | សមាជិក |

សមាជិកនៃ ***កយ*** នឹងត្រូវបានជ្រើសរើសដោយប្រធាន និងអនុប្រធាន លេខាធិការមានទីតាំងនៅការិយាល័យសម្ព័ន្ធអង្គការកូសេកាំ រហូតទាល់តែមានកន្លែងធ្វើការនៅក្នុងក្រសួងសង្គមកិច្ច។ គោលបំណងលទ្ធផលរំពឹងទុកនឹងត្រូវបានកំណត់នៅក្នុងកិច្ចប្រជុំដំបូងរបស់ *កយ* និងកិច្ចប្រជុំជាប្រូវហែរដោយ ***កយ***។ សមាជិកទាំងឡាយត្រូវតែយល់ព្រមអនុវត្តគោលការណ៍សម្ងាត់

ផ្ទាល់ខ្លួនរបស់អតិថិជន ដែលបានគេលើកមកពិភាក្សានៅក្នុងកិច្ចប្រជុំ *កឃ*។ សមាជិកត្រូវអនុវត្តន៍តាមដំណាក់កាលឱ្យបានសមស្រប ដើម្បីធានាថាឯកសារដែលត្រូវបានកត់ត្រានូវព័ត៌មានរួចហើយនោះត្រូវបានរក្សាទុកនៅកន្លែងដែលមានសុវត្ថិភាព។ សមាជិកដែលត្រូវបានរកឃើញថាបានធ្វើឱ្យធ្លាយព័ត៌មានសម្ងាត់នោះនឹងត្រូវដកចេញ។ សមាជិកទាំងអស់ត្រូវតែចុះហត្ថលេខាលើការអនុវត្តន៍នេះ។ រាល់កិច្ចប្រជុំនឹងត្រូវធ្វើឡើងដរាបណាមានកូរ៉ុម (Quorum) គ្រប់ (ចំនួនកូរ៉ុមត្រូវបានកំណត់ ១ភាគ៣ នៃសមាជិកទាំងអស់ រួមទាំងប្រធាន និងអនុប្រធានផងដែរ)។ ការសម្រេចចិត្តនឹងត្រូវធ្វើឡើងដោយផ្អែកលើគោលការណ៍ឯកច្ឆ័ន្ទ ឬបើសិនមានសមាជិកណាម្នាក់ជំទាស់ការសម្រេច ត្រូវធ្វើឡើងតាមការបោះឆ្នោត។ មតិភាគច្រើនត្រូវបានឱ្យនិយមន័យថា ៥០បូក១ នៃមតិសមាជិកទាំងអស់របស់ *កឃ* ដែលមានវត្តមាននៅទីនោះ។ សមាជិកដែលដាក់ពាក្យឈប់គួរតែស្នើឱ្យមានការផ្លាស់ប្តូរដ៏សមស្របមួយទៅដល់ប្រធាន។ ប្រធាន និងអនុប្រធាន នឹងធ្វើការតែងតាំងបេក្ខជនម្នាក់ ឬច្រើននាក់ឱ្យធ្វើការជំនួសរួមបញ្ចូលទាំងបេក្ខជនពីសមាជិកខាងក្រៅ បន្ទាប់មកធ្វើការត្រួតពិនិត្យថាតើបេក្ខជនទាំងនោះអាចទទួលតំណែងដែលនៅទំនេរនេះបានឬទេ។ *កឃ* នឹងធ្វើការបោះឆ្នោតដោយប្រើប្រព័ន្ធសន្លឹកឆ្នោតសម្ងាត់សម្រាប់ការទទួលយកនូវបេក្ខភាពថ្មីនេះ។

## តួនាទី និងការទទួលខុសត្រូវ

ការទទួលខុសត្រូវចំបងរបស់ **ប្រធាន** *កឃ*:

- ប្រធានអង្គប្រជុំ។
- ផ្ញើរបៀបវារៈទៅដល់សមាជិកផ្សេងៗ ឱ្យទាន់ពេលវេលាមុននឹងកិច្ចប្រជុំចាប់ផ្តើម។
- ពិនិត្យមើលលើការវិវឌ្ឍន៍របស់ *កឃ* និងទិដ្ឋភាពទូទៅនៃគោលបំណងរបស់វា។
- ធានាថាកិច្ចប្រជុំនិងចាប់ផ្តើម ហើយបញ្ចប់ទៅនៅត្រឹមពេលវេលាកំណត់។
- សម្របសម្រួលបង្កើតឱ្យមានការជជែក និងពិភាក្សាគ្នា។
- ធានាថា ការសម្រេចចិត្តទាំងឡាយត្រូវបានធ្វើឡើងបន្ទាប់ពីមានព័ត៌មាន និងកិច្ចពិភាក្សាដ៏សមស្រប ហើយនឹងត្រូវកត់ត្រាទុក និងរក្សាក្នុងសំណុំបញ្ជី។
- ធានាថាបណ្តាសកម្មភាពនានាត្រូវបានអនុវត្តន៍។
- ជាតំណាងរបស់ *កឃ*។
- ដោះស្រាយជម្លោះ ឬបញ្ហាផ្សេងៗក្នុងក្រុមប្រឹក្សាពិគ្រោះយោបល់ *កឃ*។
- បង្កើតនូវបណ្តាញ ដែលមានលក្ខណៈវិជ្ជមានក្នុងការជ្រើសរើសតំបន់គោលដៅអនុវត្តគម្រោង។
- អញ្ជើញតំណាងមកពីស្ថាប័ន និងអ្នកជំនាញដែលពាក់ព័ន្ធដើម្បីចូលរួមក្នុងកិច្ចប្រជុំ។
- កំណត់ពេលប្រជុំលើកក្រោយទៀត។
- ចាត់តាំងឱ្យអនុប្រធានទទួលការងារជាប្រធាននៅពេលចាំបាច់។
- រាយការណ៍ជាទៀតទាត់លើដំណើរការ និងការសម្រេចបានរបស់ *កឃ* ក៏ដូចជាបណ្តាលទ្ធផលនៃការអនុវត្តន៍គម្រោង។

ការទទួលខុសត្រូវចំបងរបស់ **អនុប្រធាន** *កយ* :

- ទទួលការងារជាប្រធាននៅពេលចាំបាច់ ។
- ធានានូវការសម្រេចគោលដៅ និងលទ្ធផល ។
- បង្កើតនូវបណ្តាញ ដែលមានលក្ខណៈវិជ្ជមានក្នុងការជ្រើសរើសគោលដៅ តំបន់អនុវត្តន៏គម្រោង ។

ការទទួលខុសត្រូវចំបងរបស់ **សមាជិក** *កយ* :

- ចូលរួមប្រជុំជាទៀងទាត់ ។
- ចូលរួមបង្កើតកិច្ចពិភាក្សាអំពីគម្រោង *គកស ។*
- ចែកចាយព័តិមាន និងគំនិតយោបល់លើប្រព័ន្ធ *គកស* រួមបញ្ចូលទាំងវិធីសាស្រ្តគ្រប់គ្រងករណី និងការអនុវត្តន៏ដែលប្រសើរបំផុត ។
- ផ្សព្វផ្សាយនូវគម្រោង *គកស* ។
- ពិនិត្យមើលឡើងវិញនូវកំណត់ហេតុ បន្ទាប់ពីកិច្ចប្រជុំនីមួយៗ ។
- ទទួលខុសត្រូវលើការងារលេខាធិការ បើសិនចាំបាច់ ។
- ត្រួតពិនិត្យមើលដំណើរការទៅមុខរបស់គម្រោង *គកស* និងជនរងគ្រោះនីមួយៗ ។
- ធានានូវកិច្ចសម្របសម្រួល និងបង្កើនទនូវភាពជាដៃគូរវាងភ្នាក់ងារដៃគូ អង្គការក្រៅរដ្ឋាភិបាល អង្គការ អន្តរជាតិ អ្នកជំនាញ បុគ្គល និងអ្នកដែលជាប់ពាក់ព័ន្ធផ្សេងៗ ។
- គាំទ្រការបង្កើតសៀវភៅណែនាំ *គកស* និងដឹងច្បាស់នូវសេចក្តីណែនាំទាំងនោះ ។
- ចូលរួមក្នុងវគ្គបណ្តុះបណ្តាល *គកស* ។
- ធ្វើការសម្រេចចិត្តតាមរយៈកិច្ចព្រមព្រៀងដោយមតិឯកច្ឆ័ន ដោយចូលរួមផ្ទាល់ក្នុងកិច្ចប្រជុំនោះ ។
- ធ្វើសេចក្តីព្រាងបណ្តាឯកសារ និងដំណើរការផ្សេងៗសម្រាប់គម្រោង *គកស* ដែលតម្រូវឱ្យមាន ។
- ជួយក្នុងការកំណត់គោលដៅដែលសមស្របនានាសម្រាប់ការអនុវត្តន៏ប្រព័ន្ធ *គកស* ។
- ធានាថា អ្នកជាប់ពាក់ព័ន្ធផ្សេងៗនៅក្នុងតំបន់គោលដៅដែលបានកំណត់នោះ គាំទ្រដល់ការអនុវត្តន៏នូវគម្រោង *គកស* នេះ ។
- ប្រតិបត្តិសកម្មភាពទាំងឡាយដែលមានទំនាក់ទំនងទៅនឹង គម្រោង*គកស* ក្នុងពេលវេលាសមស្របរួមមាន :
    - ត្រួតពិនិត្យឡើងវិញនូវរបាយការណ៍ករណី និងរៀបចំសន្និសីទ ករណីជាមួយនឹងអ្នកផ្តល់សេវា និងអ្នកជំនាញដែលត្រូវការ ។
    - ធានាថា ផែនការណ៏ករណីត្រូវបានអនុវត្តតាម ។
    - រៀបចំតាមដានសន្និសីទករណី ដើម្បីពិភាក្សាលើដំណើរការ ឬការផ្លាស់ប្តូរផែនការ បើសិនជាមានសំណូមពរពីជនរងគ្រោះ ។
    - ប្រាប់ទៅដល់ផ្នែកបញ្ចូលទិន្នន័យកណ្តាលបន្ទាប់ពីធ្វើសមាហរណកម្មជនរងគ្រោះទៅក្នុងសហគមន៏វិញបានជោគជ័យនោះ ។

ការទទួលខុសត្រូវចំបងរបស់ **លេខាធិការដ្ឋាន :**

- គាំទ្រដល់ *កឃ* ។
- ព្រាងសំបុត្រអញ្ជើញសម្រាប់អញ្ជើញសមាជិកដែលត្រូវបានស្នើជាបេក្ខភាពសម្រាប់ *កឃ* ។
- ទទួល និងផ្ញើបញ្ជីទំនាក់ទំនងសមាជិកស្នើជាបេក្ខភាព *កឃ* ទៅឱ្យ *កឃ* ។
- ផ្តល់ និងរៀបចំបន្ទប់ប្រជុំ ។
- ព្រាងរបៀបវារៈសម្រាប់កិច្ចប្រជុំនីមួយៗ និងផ្តល់របៀបវារៈទាំងនោះទៅដល់ប្រធានឱ្យទាន់ពេលវេលាមុនពេលកិច្ចប្រជុំចាប់ផ្តើម ។
- ព្រាង និងចែកកំណត់ហេតុប្រជុំបន្ទាប់ពីកិច្ចប្រជុំនីមួយៗ ។
- រក្សាទុកនូវកំណត់ហេតុប្រជុំទាំងឡាយដែលបានព្រមព្រាង ។
- ធានាថាចំណុចសកម្មភាពផ្សេងៗ ពីកិច្ចប្រជុំមុនៗត្រូវបានបំពេញ ។

**ការត្រួតពិនិត្យ និងវាយតម្លៃ**

***កឃ*** រួមចំណែកក្នុងការត្រួតពិនិត្យ និងវាយតម្លៃទៅលើការវិនិច្ឆ័យ សាកល្បងនៃគម្រោង *គកស* ។ មុននឹងកិច្ចការ *គកស* ចាប់ផ្តើម *កឃ* នឹងស្វែងរកជំនួយពីអ្នកជំនាញដើម្បីជួយបង្កើតឯកសារការអនុវត្តទីល្អៗនៃការត្រួតពិនិត្យ និងឧបករណ៍វាយតម្លៃ និងដំណើរការផ្សេងៗ ។ *កឃ* នឹងរាយការណ៍អំពីលទ្ធផលនៃការត្រួតពិនិត្យ និងវាយតម្លៃជូនភ្នាក់ងាររដ្ឋាភិបាល អង្គការក្រៅរដ្ឋាភិបាល អង្គការអន្តរជាតិ និងភ្នាក់ងារដែលពាក់ព័ន្ធ និងបុគ្គលផ្សេងៗទៀត ។ ផ្អែកលើលទ្ធផលនៃការត្រួតពិនិត្យ និងវាយតម្លៃ *កឃ* នឹងផ្តល់នូវអនុសាសន៍ថាតើគួរតែបញ្ឈប់គម្រោង *គកស* ឬក៏បន្តពង្រីកគម្រោងនេះពាសពេញប្រទេសកម្ពុជា តាមរយៈការផ្តល់ជំនួយ និងភ្នាក់ងារគាំពារតទៅទៀតឬយ៉ាងណា ។

**លេខាធិការដ្ឋាន :** បន្ទប់លេខ ៥៩៤ ជាន់ទី៥ មជ្ឈមណ្ឌលភ្នំពេញ កាច់ជ្រុងមហាវិថី ព្រះសីហនុ និងវិថីសុធារស សង្កាត់ទន្លេបាសាក់ ខ័ណ្ឌចំការមន រាជធានីភ្នំពេញ ប្រអប់សំបុត្រលេខ ៥៧៤ ។

ទូរស័ព្ទ : (៨៥៥) ២៣ ៩៩៣ ៦៧៥ / (៨៥៥) ២៣ ២២៤ ៨០១

អ៊ីម៉ែល : office@cosecam.org

វេបសាយ : www.cosecam.org

# COSECAM PUBLICATIONS

01- Annual report 2003
02- Advocacy Training Report: Lobby and Advocacy: Methods and Principles, 2003
03- Minimum Standard for Shelter, by Sim Souyoung, March 2003 (Khmer & English Version)
04- Minimum Standards for Residential Child Care, by Sim Souyoung, March 2003 (Khmer & English Version)
05- Exchange Visits to Centers: NGO Child Rehabilitation Centers in Cambodia, Reviewed by Amanda Mclaughlin, May 2003
06- Victims of Trafficking Workshop Report 1, Sold like Chickens: Trafficked Cambodian Girls Speak Out, by Sandy Hudd, May 2003 (Khmer & English Version)
07- Training Investigation Manual: Investigation of Commercial Sexual Exploitation of Children and Child Sexual Abuse in Cambodia (Khmer & English Version), 2003
08- Child Recovery Centers: Intentions versus Realities, by John Vijghen, 2003
09- Campaign Against Child Exploitation in Cambodia Report, May 2004
10- Victims of Trafficking Workshop Report 2, Tricked by the Trade: Trafficked Cambodian Girls Speak Out, by Diane Lawrence, May 2004
11- National Conference Report on Effective Strategies to Eliminate Sexual Trafficking and Exploitation of Children in Cambodia, August 2004
12- Job and Business Search for Young Woman Project, by Lucid Cube Consulting, September 2004
13- Cambodian Commodity Chain analysis study, Volume 1: Comparative Industry Assessments, by Lucid Cube Consulting, September 2004
14- Cambodian Commodity Chain analysis study, Volume 2: Job Facilitation Program Recommendations, by Lucid Cube Consulting, September 2004
15- Impact of Closing Svay Pak Research Report, by Dr. Frédéric Thomas, January 2005
16- New Practices of Prostitution Research Report, by So Sokbunthet, June 2005
17- Situation Analysis of Paedophilia in Sihanouk Ville Research Report, by Judith Von Gyer June 2005
18- Goods & Girls: Trade Across Borders, by John L. Vijghen, Khun Sithon, 2005
19- Child Sex Tourism: Study of the Scope of the Problem and Evaluation of Existing Anti-Child Sex Tourism Initiatives, by Caroline Putman-Cramer, 2005
20- COSECAM Evaluation Report, by Lucid Cube Consulting, 2005.
21- Stories from The Heart: Girls Speak Out – Three Years On, by COSECAM Advocacy Team, 2007
22- Agreement on Guidelines for Practices and Cooperation between the Relevant Government Institutions and Victim Support Agencies In Cases of Human Trafficking
23- Integrated Child Issue Programming: The Survey of Situational Analysis on Integrated Programming to Combate Child Trafficking and Exploitation in Cambodia, conducted by IHRD Team, July 2007
24- COSECAM Annual Report 2004-2006, Published October 2007
25- Situation Analysis of the Commercial Sexual Exploitation of Children in the Kingdom of Cambodia: 2006-2007. Published December 2007
26- NGO Joint Statistics: Database Report on Trafficking and Rape in Cambodia 2005-2006. Published 2008
27- COSECAM's Delegates Meeting Record, October 2008
28- Annual Report 2007, Published November 2008
29- Coordinated Case Management: A National Coordinated System for Decentralized Services to Victims of Exploitation and Violence, October 2008